

# សេចក្តីថ្លែងការណ៍រួម

## វេទិកាកសិករថ្នាក់ជាតិលើកទី ១១

“ធ្វើការក្នុងភាពជាដៃគូក្នុងការលើកកម្ពស់សមត្ថភាពបន្សុំរបស់កសិករខ្នាតតូចទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីឆ្លើយតបតម្រូវការទីផ្សារកសិផល”

រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០២៣

*យើងទាំងអស់គ្នាតំណាងឱ្យកសិករខ្នាតតូច និងមធ្យម សហគមន៍កសិកម្មមកពី ១៨ ខេត្ត/ក្រុង រួមមាន ភ្នំពេញ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប ព្រះវិហារ កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម ក្រចេះ ព្រៃវែង ស្វាយរៀង កណ្ដាល តាកែវ កំពត កំពង់ស្ពឺ កោះកុង និងអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យកសិកម្ម សូមគោរពដាក់ជូននូវសេចក្ដីថ្លែងការណ៍រួមដែលជាលទ្ធផលនៃកិច្ចពិភាក្សាក្នុង**វេទិកាកសិករថ្នាក់ជាតិលើកទី១១** ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមប្រធានបទៈ **ធ្វើការក្នុងភាពជាដៃគូក្នុងការលើកកម្ពស់សមត្ថភាពបន្សុំារបស់កសិករខ្នាតតូចទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុដើម្បីឆ្លើយតបតម្រូវការទីផ្សារកសិផល** ។*

*វេទិកានេះ មានអ្នកចូលរួមសរុបចំនួន ១៧៧នាក់ (ស្រ្តី ៦៣នាក់) មកពីតំណាងស្ថាប័នពាក់ព័ន្ធរួមមាន តំណាងរាជរដ្ឋាភិបាល តំណាងកសិករខ្នាតតូច និងមធ្យម សហគមន៍កសិកម្ម វិស័យឯកជន ធនាគារ និងមីក្រូហិរញ្ញវត្ថុ ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា។ វេទិកានេះរៀបចំឡើងក្នុងគោលបំណងៈ ទី១)ពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តនូវអនុសាសន៍ ដែលបានលើកឡើង នៅក្នុងវេទិកាកសិករថ្នាក់ជាតិលើកទី១០ ទី២)ជំរុញឲ្យមានគំរូកសិធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដែលគាំទ្រដល់ការពង្រឹងសេដ្ឋកិច្ចរបស់ស្រ្តី និងភាពធនទៅនឹង អាកាសធាតុ នៅកម្ពុជា និងទី៣)ផ្ដល់ឱកាសដល់ភាគីពាក់ព័ន្ធដើម្បីពិភាក្សា កំណត់នូវទិសដៅអាទិភាព និងធ្វើការក្នុងភាពជាដៃគូសម្រាប់ជួយគាំទ្រដល់កសិករខ្នាតតូចក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុអោយកាន់តែប្រសើរឡើងដើម្បីដោះស្រាយបញ្ហាប្រឈមដែលពួកគាត់កំពុងជួបប្រទះក្នុងវិស័យកសិកម្មនៅកម្ពុជា។ សេចក្ដីថ្លែងការណ៍ ចែកចេញជាបីផ្នែកធំៗរួមមានៈ សមិទ្ធផលដែលសម្រេចបានដោយភាគីពាក់ព័ន្ធទាំងអស់ បញ្ហាប្រឈម និងអនុសាសន៍ ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធនានា ដើម្បីពិនិត្យពិចារណាដាក់បញ្ចូលទៅក្នុងផែនការអនុវត្តរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់កសិករខ្នាតតូច និងមធ្យម។*

# សមិទ្ធផល

1. ដើម្បីឆ្លើយតបនឹងវិបត្តិកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានពិសេស ដែលមានទឹកប្រាក់រហូតដល់ ១០០លានដុល្លារ គិតត្រឹមឆ្នាំ ២០២២ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។ ចំពោះឥណទានរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម គឺ ៖ ១) មានអត្រាការប្រាក់ទាប ២) មិនផាកពិន័យអ្នកកម្ចីដែលបានបង់យឺតយ៉ាវ ដោយមានដំណោះស្រាយដែលអាចទទួលយកបានពីភាគីទាំងសងខាង។ ធនាគារក៏មានគោលបំណងផ្សារភ្ជាប់ទីផ្សារជូនកសិករដូចជា ក្រុមអ្នកដាំបន្លែ និងក្រុមអ្នកចែកចាយបន្លែ។ យុទ្ធសាស្ត្ររបស់ធនាគារ គឺជួយសម្រួលដល់អ្នកខ្ចី តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយ៣ភាគី រួមមាន សហគមន៍កសិកម្ម ក្រុមហ៊ុនទិញ (រោងម៉ាស៊ីនកិនស្រូវ) និងធនាគារ ។ ដោយបានទទួលការឯកភាពពីរាជរដ្ឋាភិបាល អត្រាការប្រាក់របស់ធនាគារនៅឆ្នាំ ២០២២ គឺចាប់ពី ៧% ក្នុង១ឆ្នាំ ទៅតាម ប្រភេទនិង ទំហំនៃកម្ចី ។ ក្រៅពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម រាជរដ្ឋាភិបាលក៏បានធ្វើអន្តរាគមន៍ដាក់ចេញនូវគោលនយោបាយ និងសម្របសម្រួលជាមួយវិស័យឯកជន និងធនាគារឯកជន ដើម្បីជួយសហគមន៍កសិករក្នុងបញ្ហាកម្ចី និងសំណងប្រាក់។

2. តាមរយៈគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) កសិករមានទីផ្សារក្នុងមូលដ្ឋាន ឬនៅតាមទីក្រុងនានា រៀងរាល់ចុងសប្តាហ៍ ដែលបង្កលទ្ធភាពអោយ កសិករអាចយកកសិផលទៅលក់បានងាយស្រួលជាងពេលមុន។ មកដល់ពេលនេះ ទីផ្សារសហគមន៍មាននៅក្នុងខេត្តចំនួន១៨រួចហើយ។ ក្រៅពីនោះ កសិករក៏អាចទទួលបានប្រាក់កម្ចីមកពង្រីកមុខរបររបស់ពួកគាត់ក្នុងទំហំសាច់ប្រាក់ប្រមាណ ១៥០០ដុល្លារ រយៈពេល២ឆ្នាំក្នុងមួយគ្រួសារ។

3. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរអគ្គិសនីកម្ពុជា បានបន្តបញ្ចុះថ្លៃអគ្គិសនីសម្រាប់ការប្រើប្រាស់ក្នុងវិស័យ កសិកម្ម តាមរយៈការដាក់ចេញនូវគោលការណ៍ និងនីតិវិធីនៃការអនុវត្តន៍អត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើ ពេលយប់ គ្រប់ប្រភេទក្នុងវិស័យកសិកម្មក្នុងតំបន់ ផ្គត់ផ្គង់អគ្គិសនី ដែលទទួលប្រភព ពីបណ្តាញជាតិ។

4. រាជរដ្ឋាភិបាល បានសម្រេចចេញច្បាប់បង្កើតសមាគមកសិកម្មនៅឆ្នាំ ២០១៣ ។

5. ក្រសួងធនធានទឹក និងឧតុនិយម បានបន្តបង្កើនចំនួនប្រព័ន្ធធារាសាស្ត្ររហូតដល់៣០០ប្រព័ន្ធ ដើម្បីឲ្យបានសមស្របទៅតាមផ្ទៃដីកសិកម្មដែលកើនឡើងប្រមាណ ៣លានហិកតា គិតត្រឹមឆ្នាំ ២០២២។

6. ក្រសួងកិច្ចការនារី បានធ្វើកិច្ចការបញ្ជ្រាបយេនឌ័រ តាមរយៈផែនការយុទ្ធសាស្ត្រ "នារីរតនៈ" ដែលផ្តល់ឱកាសជូនស្ត្រី និងបុរសសហការគ្នាក្នុងការងារកសិកម្ម ពិសេសស្ត្រីទទួលបានសិទ្ធិកាន់តែច្រើនឡើងក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលក៏មានយុទ្ធសាស្ត្រលើកកម្ពស់ និងបង្កើនចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ដែលបច្ចុប្បន្នមាន២០% ជាស្ត្រីក្នុងជួរថ្នាក់ដឹកនាំរបស់រដ្ឋ។

7. ក្រសួងអភិវឌ្ឍន៍ជនបទ បន្តកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ពិសេស ការកសាងផ្លូវតាមជនបទ ដែលជួយសម្រួលដល់ការដឹកជញ្ជូនសម្ភារៈកសិកម្ម និងកសិផលទៅតាមទិសដៅនានា។ ជាងនេះទៅទៀត តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានបង្កើត«គម្រោងសម្បត្តិ» ដើម្បីជួយសម្រួលក្នុងការកសាងផ្លូវក្នុងសហគមន៍ ដែលផលិតដំណាំកសិកម្ម ស្របតាមការចុះសិក្សារបស់គម្រោង។ ទន្ទឹមនោះដែរ ក៏មានផ្តល់អណ្តូងទឹក កិច្ចការអនាម័យតាមគ្រួសារ និងការពង្រឹង និងបណ្តុះបណ្តាលសហគមន៍ជនបទឲ្យមានសមត្ថភាពកាន់តែខ្ពស់ឡើងក្នុងការគ្រប់ការងារកសិកម្មដូចជាសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលសអាកាសធាតុជាដើម។ ក្នុងនោះដែរ ផ្លូវតាមជនបទបាននិងកំពុងទទួលផលប៉ះពាល់ជាច្រើនពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ អាស្រ័យហេតុនេះ ការបង្កើនគុណភាពផ្លូវស្របតាមលក្ខខណ្ឌអាកាសធាតុ និងទីតាំងភូមិសាស្ត្រគឺជាការចាំបាច់។ ឧ. ផ្លូវបេតុងដែលអាចធន់នឹងការលិចទឹកជាប្រចាំនៅរដូវវស្សា។ ទម្រង់ផ្លូវដែលបត់បែនតាមស្ថានភាពទឹកលិច ដូចជាត្រូវកសាងផ្លូវ "បង្ហៀរទឹក" ក្នុងតំបន់ទំនាបៗ ដើម្បីឲ្យទឹកហូរខាងលើផ្លូវជាដើម។

## បញ្ហាប្រឈម

*ដោយឈរលើពាក្យស្លោក "**ទឹក ទុន ទីផ្សារ**" ការពង្រីកបរិមាណ គុណភាព និងសោភណ្ឌភាពកសិកផល កសិករបាននឹងកំពុងជួបប្រទះបញ្ហានានាដូចខាងក្រោម៖*

1. ប្រភពទឹក និងបរិមាណទឹកសម្រាប់ប្រើប្រាស់ក្នុងការងារកសិកម្មនៅតែជាបញ្ហាចោទចំពោះកសិករ ។
2. ធាតុចូលកសិកម្មដូចជា ពូជស្រូវ ពូជដំណាំ ជី និងប្រេងឥន្ទនៈជាដើម នៅតែមានតម្លៃខ្ពស់ រួមទាំងអត្រាការប្រាក់ខ្ពស់ ដែលធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណូល និងមិនអាចប្រកួតប្រជែងតម្លៃផលិតផលកសិកម្មលើទីផ្សារបាន ជាពិសេសកសិផលនាំចូលពីប្រទេសជិតខាង។
3. សមត្ថភាពកសិករក្នុងការអនុវត្តន៍បច្ចេកទេសកសិកម្មនៅមានកម្រិតទាបនៅឡើយ មិនអាចបំពេញសេចក្តីត្រូវការទីផ្សារក្នុងប្រទេសនៅឡើយទេ។

4. ដោយសារចំណេះដឹង និងសមត្ថភាពស្ត្រីនៅតែមានចំណែកទាបក្នុងការសម្រេចចិត្ត និងចាត់ចែងសេដ្ឋកិច្ចគ្រួសារ បើទោះជាមានសកម្មភាពគម្រោងនានាជួយលើកកម្ពស់តួនាទីរបស់ស្ត្រីខ្លះៗហើយក៏ដោយ។
5. កសិករ បាននិងកំពុងជួបប្រទះបញ្ហាក្នុងការផលិតពូជស្រូវសុទ្ធ ដោយសារមានការបន្លំចែកចាយពូជមិនសុទ្ធក្នុងទីផ្សារនាំអោយប៉ះពាល់ដល់អ្នកផលិតពូជល្អ។
6. ការយល់ដឹងអំពីកត្តាអាកាសធាតុ និងទំនាក់ទំនងរវាងអាកាសធាតុ និងសកម្មភាពកសិកម្ម និងការគ្រប់គ្រងធនធានទឹក និងដី នៅមានកម្រិតទាប។

## សំណូមពរ និងអនុសាសន៍

### ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

1. គួរបន្តបង្កើនកញ្ចប់ថវិកាទៅថ្នាក់ក្រោមជាតិតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគាំទ្រ កសិករខ្នាតតូច និងមធ្យមទៅដល់សហគមន៍កសិកម្ម។
2. គួរបង្កើនវេទិកាសន្ទនាគោលនយោបាយថ្នាក់ជាតិ ដែលបង្កលទ្ធភាពឲ្យកសិករបានជួបប្រាស្រ័យទាក់ទង ផ្ទាល់ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីចែករំលែកព័ត៌មាន បញ្ហាប្រឈមនានា ព្រមទាំងស្វែងរកដំណោះស្រាយសមស្រប។
3. ជំរុញការវិនិយោគការផលិតធាតុចូលកសិកម្មក្នុងស្រុកដូចជាជីសរីរាង្គ ថ្នាំកសិកម្ម សម្ភារៈកសិកម្មដែលមានគុណភាព និងតម្លៃប្រកួតប្រជែង។
4. ពង្រឹងសមត្ថភាពដល់សហគមន៍កសិកម្មលើជំនាញសំខាន់ៗដូចជា៖ ១)ការកែច្នៃ និងវេចខ្ចប់ផលិតផលកសិកម្ម ជាពិសេសការគាំទ្រនិងផ្តល់សម្ភារៈសម្រាប់កែច្នៃដល់កសិករខ្នាតតូច និងមធ្យមទៅតាមសហគមន៍កសិកម្ម និង២)ការចាត់ចែង គ្រប់គ្រង និងការប្រើប្រាស់ទឹក។
5. គាំទ្របច្ចេកទេសកសិកម្ម ការផលិតពូជ និងការអនុវត្តស្តង់ដាកសិផល។
6. គាំទ្រនូវការបណ្តុះបណ្តាលជំនាញបច្ចេកទេសថ្មីៗ ជ្រើសរើសកសិកម្មដែលសម ស្របទៅនឹងស្ថានភាពអាកាសធាតុ និងផ្តល់ព័ត៌មានព្យាករណ៍អាកាសធាតុសម្រាប់ផ្នែកកសិកម្ម និងធនធានទឹក។
7. ពង្រឹងការត្រួតពិនិត្យ និងតាមដានដើម្បីធានាគុណភាពផលិតផលកសិកម្ម។
8. បង្កើនខ្សែច្រវ៉ាក់តម្លៃកសិកម្មដូចជា ការផលិត កែច្នៃ និងវេចខ្ចប់ ជាពិសេសការជំរុញកសិធុរកិច្ច។
9. បង្កើនទីផ្សារលក់ផលិតផលសហគមន៍ឲ្យបានយ៉ាងតិចចំនួន១ ក្នុង១ខេត្ត។

10. ជំរុញ និងពង្រឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាអោយកាន់តែទូលំទូលាយ។
11. ពន្លឿនការអនុម័តច្បាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងចែករំលែកសេចក្តីព្រាងច្បាប់ ព្រមទាំងផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល និងសហគមន៍កសិកម្ម អោយបានចូលរួមផ្តល់ធាតុចូលក្នុងដំណើរការតាក់តែងច្បាប់។
12. គាំទ្រផលិតផលរបស់កសិករតាមរយៈការផ្តល់លិខិតទទួលស្គាល់ប្រភេទស្រូវ ដើម្បីងាយស្រួលក្នុងការលក់ចេញទៅអោយក្រុមហ៊ុនទទួលទិញ។ ទន្ទឹមគ្នានេះ ស្ថាប័នពាក់ព័ន្ធគួរបង្កើនប្រសិទ្ធភាពយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងកសិករ និងក្រុមហ៊ុនវិនិយោគលើវិស័យស្រូវអង្ករជាដើម។
13. គាំទ្រការពង្រឹងអំណាចសេដ្ឋកិច្ចស្ត្រី ក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម ជាពិសេសរាល់ ការអនុវត្តគម្រោងជាមួយដៃគូពាក់ព័ន្ធ។

## ក្រសួងធនធានទឹក និងឧតុនិយម

*គួរបន្តជួសជុលស្តារប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រព និងអភិវឌ្ឍន៍អាង ទឹកធំៗ ដើម្បីរក្សាទឹកទុកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងសំរាប់ការធ្វើកសិកម្ម។*

## ក្រសួងអភិវឌ្ឍន៍ជនបទ

*គួរជំរុញការកសាងស្ថាបនាផ្លូវជនបទដែលធន់ទៅនឹងអាកាសធាតុ ដើម្បីតភ្ជាប់ កសិផលទៅដល់ទីផ្សារ និងជួយកាត់បន្ថយការចំណាយលើថ្លៃដឹកជញ្ជូន។*

## ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

1. គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុគួរបន្តផ្តល់អត្រាការប្រាក់សមស្របសម្រាប់កម្ចីកសិកម្មដល់កសិករ សម្រួលបែបបទរដ្ឋបាល នីតិវិធី និងបន្ធូរបន្ថយ លក្ខខណ្ឌក្នុងការស្នើសុំកម្ចី ក៏ដូចជាទ្រព្យធានាជាដើម។ ឧ. ប្រើត្រឹមតែកិច្ចព្រមព្រៀងកសិកម្ម ឬកិច្ចសន្យាកសិកម្ម។ ព្រមជាមួយនេះដែរ គួរផ្តល់អ្នកជំនាញ ប្រឹក្សាផ្នែកកសិកម្ម ដើម្បីជួយកាត់បន្ថយហានិភ័យផ្សេងៗ។
2. ចំពោះលក្ខខណ្ឌសងត្រឡប់វិញ គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ គួរបង្កើតអោយមាននូវជម្រើសច្រើន ដើម្បីផ្តល់លទ្ធភាពអោយកសិករអាចសងត្រឡប់វិញ និងផ្តល់ការអនុគ្រោះនៅពេលមានប្រធានស័កកើតឡើងជាដើម។

3. ក្រុមហ៊ុនឯកជនគួរបង្កើនកិច្ចសហប្រតិបត្តិការជាមួយសហគមន៍កសិកម្ម ដើម្បីជំរុញការអនុវត្តពាក់កណ្តាលកែច្នៃដែលអាចជួយជំរុញចំណូលនៅតាមសហគមន៍បន្ថែមពីលើចំណូលពីការផលិត។
4. ក្រុមហ៊ុនឯកជនគួរផ្តល់ទុនមុន ៣០% ដល់កសិករ ឬសហគមន៍កសិកម្មអំឡុងពេលប្រមូលទិញផលិតផលកសិកម្ម ដើម្បីអោយគាត់មានលទ្ធភាពក្នុងការប្រមូលទិញពីសមាជិកសហគមន៍។
5. ក្រុមហ៊ុនឯកជនគួរតែបង្កើនការវិនិយោគលើការកែច្នៃកសិផលរបស់កសិករ។
6. ក្រុមហ៊ុនឯកជន គួរមានភាពស្មោះត្រង់ជាមួយកសិករ ក្នុងការអនុវត្តកិច្ចសន្យា ផលិតកម្មកសិកម្ម។

## កសិករខ្នាតតូច-មធ្យម និងសហគមន៍កសិកម្ម

1. កសិករគួរប្រើប្រាស់ជីធម្មជាតិ ជំនួសជីគីមី ដើម្បីរក្សាគុណភាពដី។ ប្រព័ន្ធដំណក់ទឹក ក៏ជួយរក្សាគុណភាពដីដែរ ។ ទន្ទឹមនេះ ក៏គួរធ្វើកសិកម្មដំណាំចំរុះ ដោយប្តូរប្រភេទដំណាំតាមរដូវ និងឆ្លាស់ដំណាំគ្នាតាមរងដំណាំ។
2. កសិករគួរប្រើប្រាស់ពូជដំណាំ ដែលមានគុណភាពល្អ ជាពិសេសពូជដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងសត្វល្អិតចង្រៃ។
3. កសិករគួរអនុវត្តន៍តាមគោលការណ៍ស្តង់ដារនៃការអនុវត្តកសិកម្មល្អ (GAP, Good Agriculture Practice) ដើម្បីធានាសុវត្ថិភាពផលិតផលកសិកម្ម។
4. កសិករគួរចងក្រងជាបណ្តុំ ឬជាសហគមន៍កសិកម្ម សំដៅពង្រឹងសមត្ថភាព និងការអនុវត្តសកម្មភាពអភិបាលកិច្ចល្អ ដើម្បីនិរន្តរភាពសហគមន៍កសិកម្ម ជាពិសេស នៅពេលដែលមិនមានការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។
5. ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ពិសេសទីផ្សារទំនើប កសិករគួរចងក្រងជាសហគមន៍កសិកម្ម និងមានផែនការផលិតអោយបានច្បាស់លាស់ព្រមទាំងគោរពតាមកិច្ចសន្យាផលិតកម្មកសិកម្ម ។
6. កសិករគួរមានភាពស្មោះត្រង់ ជាមួយក្រុមហ៊ុនឯកជន ក្នុងការអនុវត្តកិច្ចសន្យា ផលិតកម្មកសិកម្ម។
7. សហគមន៍កសិកម្មគួរប្រែក្លាយទៅជាសហគ្រិន និងពង្រឹងភាពដៃគូជាមួយអ្នកពាក់ព័ន្ធដូចជាក្រុមហ៊ុនឯកជន  និងអង្គការ ដើម្បីទទួលបានការគាំទ្របន្ថែម។
8. ជម្រុញការប្រើប្រាស់ថាមពលកកើតឡើងវិញនៅក្នុងខ្សែច្រវ៉ាក់ផលិតកសិកម្ម ដើម្បី កាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្ម។

## អង្គការកសិករ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍សហការរៀបចំវេទិកាកសិករថ្នាក់ជាតិលើកទី១១

| ល.រ | ឈ្មោះជាភាសាខ្មែរ | ល.រ | ឈ្មោះជាភាសាខ្មែរ |
|---|---|---|---|
| ១ | អង្គការជំនួយព្រះវិហារហ្វាំងឡង់ | ២០ | តំណាងកសិករស្ត្រីផ្ទើម |
| ២ | អង្គការជំនួយវិហារដាណឺម៉ាក | ២១ | អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ៣ | អង្គការអាក់សិនអេតកម្ពុជា | ២២ | អង្គការសហព័ន្ធអភិវឌ្ឍន៍កសិកម្មចម្រុះកម្ពុជា |
| ៤ | អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ | ២៣ | អង្គការក្រុមទ្រទ្រង់ភូមិ |
| ៥ | អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ | ២៤ | អង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា |
| ៦ | អង្គការអុកស្វាម | ២៥ | អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ |
| ៧ | អង្គការមជ្ឈមណ្ឌលម្ចប់ព្រហ្មវិហារធម៌ | ២៦ | អង្គការជំនួយជនបទ |
| ៨ | អង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព | ២៧ | សមាគមសង្ឃគហធម៌ |
| ៩ | អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ | ២៨ | សមាគមភ្នំនាងកង្រី |
| ១០ | អង្គការសាមគ្គីពន្លឺថ្មី | ២៩ | អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ |
| ១១ | សមាគមបណ្តាញកសិករនិងធម្មជាតិ | ៣០ | អង្គការអភិវឌ្ឍន៍ និងការការពារបរិស្ថាន |
| ១២ | បណ្តាញកសិករ និងទឹក | ៣១ | អង្គការរចនា |
| ១៣ | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ | ៣២ | អង្គការចិត្តធម៌ |
| ១៤ | អង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ | ៣៣ | សមាគមអភិវឌ្ឍន៍ភូមិ |
| ១៥ | អង្គការជីវិតថ្ងៃថ្នូរ | ៣៤ | អង្គការនាគព័ន្ធដើម្បីអភិវឌ្ឍន៍ |
| ១៦ | អង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា | ៣៥ | អង្គការសង្គ្រោះជនទុរគត និងមនុស្សចាស់ |
| ១៧ | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា | ៣៦ | សមាគមសហព័ន្ធជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា |
| ១៨ | សមាគមភាពជាដៃគូដើម្បីអភិវឌ្ឍន៍ធនធានមនុស្សនៅជនបទ | ៣៧ | អង្គការបំប៉នវិជ្ជាជីវៈ អភិវឌ្ឍន៍សេដ្ឋកិច្ចនិងកសិកម្មជនបទ |
| ១៩ | អង្គការអ្នកក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន | ៣៨ | អង្គការអភិវឌ្ឍន៍ជនបទភាគឦសាន |